អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១០

# ការិយាល័យសហព្រះរាជអាជ្ញា

## សេចក្ដីប្រកាសព័ត៌មាន

### ការកំណត់កាលបរិច្ឆេទចុងក្រោយសម្រាប់ពាក្យបណ្ដឹង ក្នុងសំណុំរឿងលេខ ០០២

នៅថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេត បានជូនដំណឹងដល់គ្រប់គូភាគីទាំងអស់ នៅក្នុងកិច្ចដំណើរការនីតិវិធីថា ខ្លួនពិចារណាអំពីការបិទកិច្ចស៊ើបសួរ ក្នុងសំណុំរឿងលេខ ០០២ ។ ខណៈដែលសេចក្ដីប្រកាសរបស់សហចៅក្រមស៊ើបអង្កេតជូនដំណឹងថា កិច្ចស៊ើបសួរកំពុងតែស្ថិតក្នុងដំណាក់កាលចុងក្រោយ គេនៅមានពេលវេលា និងឱកាសសម្រាប់ភស្តុតាងបន្ថែមដែលត្រូវប្រមូលនិងដាក់បញ្ចូលទៅក្នុងសំណុំរឿងលេខ០០២ ។

វិធាន៤៩ នៃវិធានផ្ទៃក្នុងសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក”) ផ្ដល់សិទ្ធិដល់សហព្រះរាជអាជ្ញា ក្នុងភារកិច្ចវាយតម្លៃលើពាក្យបណ្ដឹង ឬព័ត៌មានផ្សេងៗដែលកំពុងដំណើរការ ដែលចោទប្រកាន់អំពីការប្រព្រឹត្តឧក្រិដ្ឋកម្ម នៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ។ បើសិន សហព្រះរាជអាជ្ញាបានទទួលពាក្យបណ្ដឹង ឬព័ត៌មានពាក់ព័ន្ធនឹងកិច្ចស៊ើបសួរដែលកំពុងតែដំណើរការ សហព្រះរាជអាជ្ញា អាចបញ្ជូនពាក្យបណ្ដឹង ឬពត៌មាននោះទៅសហចៅក្រមស៊ើបអង្កេត ដើម្បីដាក់ទៅក្នុងសំណុំរឿងធ្វើជាភស្តុតាង ។ ពាក្យបណ្ដឹង ឬព័ត៌មានទាំងនេះអាចនឹងត្រូវបានដាក់ជូនមកសហព្រះរាជអាជ្ញា តាមរយៈអង្គភាពជនរងគ្រោះ ដោយបុគ្គលណាម្នាក់ អង្គការណាមួយ ឬ ប្រភពផ្សេងទៀត ដែលជាសាក្សី ឬធ្លាប់ជាជនរងគ្រោះនៃឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ឬជនដែលមានព័ត៌មាន អំពីបទឧក្រិដ្ឋដែលបានចោទប្រកាន់នោះ ។ ដូចដែលការកំណត់កាលបរិច្ឆេទចុងក្រោយសម្រាប់ទទួលពាក្យបណ្ដឹងមិនមានចែងជាក់លាក់នៅក្នុងវិធានផ្ទៃក្នុងទេ សហព្រះរាជអាជ្ញា មានទស្សនៈយល់ឃើញថា ការកំណត់កាលបរិច្ឆេទចុងក្រោយសម្រាប់ទទួលពាក្យបណ្ដឹងទាក់ទងនឹងសំណុំរឿងលេខ ០០២ គឺជាការចាំបាច់សម្រាប់គោលបំណងច្បាប់ និងភស្តុភារ ។

ដោយមានការពិគ្រោះយោបល់គ្នាជាមួយអង្គភាពជនរងគ្រោះ សហព្រះរាជអាជ្ញា បានកំណត់យក **ថ្ងៃច័ន្ទ ទី៨ ខែកុម្ភៈ ឆ្នាំ២០១០** ធ្វើជាកាលបរិច្ឆេទកំណត់សម្រាប់ការយល់ព្រមទទួលពាក្យបណ្ដឹងរបស់ជនរងគ្រោះនានា ដែលអាចនឹងត្រូវបានបញ្ជូនដើម្បីដាក់បញ្ចូលទៅក្នុងសំណុំរឿងលេខ ០០២ នៅក្នុងដំណាក់កាលនៃកិច្ចស៊ើបសួរ ។

ជនណាដែលមានបំណងដាក់ពាក្យបណ្ដឹងទាក់ទិននឹងសំណុំរឿងលេខ ០០២ គួរដាក់ពាក្យបណ្ដឹងឲ្យបានទាន់ពេលវេលា តាមរយៈការដាក់ពាក្យបណ្ដឹងទៅអង្គភាពជនរងគ្រោះ មិនឲ្យហួសកាលបរិច្ឆេទកំណត់ដូចខាងលើនេះ ។

កាលបរិច្ឆេទកំណត់នេះ មិនបានធ្វើការច្រានចោលជាមុន ឬធ្វើឲ្យជនណាម្នាក់ បាក់ទឹកចិត្តលែងហ៊ានដាក់ពាក្យបណ្ដឹងនៅក្រោយកាលបរិច្ឆេទខាងលើនេះទេ ។ ក៏ប៉ុន្តែ សូមធ្វើការណែនាំយ៉ាងទទូចថា គួរតែដាក់ពាក្យបណ្ដឹងឲ្យបានមុនកាលបរិច្ឆេទនេះប្រយោជន៍នឹងធានាឲ្យប្រាកដថា ពាក្យបណ្ដឹងអាចនឹងមានលទ្ធភាពខ្ពស់ជាង ក្នុងការទទួលយកសម្រាប់ធ្វើជាភស្តុតាងនៅក្នុងសំណុំរឿងលេខ ០០២ ។

ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះសម្រាប់ជនរងគ្រោះបំពេញ អាចរកបាននៅក្នុងអាសយដ្ឋាននៃគេហទំព័រដូចខាងក្រោមនេះ៖ http://www.ecccc.gov.kh/engkish/vu_form.aspx ឬអាចរកបាននៅអង្គភាពជនរងគ្រោះ, មណ្ឌលពត៌មាននៃ អ.វ.ត.ក ដែលមានអាសយដ្ឋានលេខ: ៦ក, ផ្លូវលេខ២១, សង្កាត់ទន្លេបាសាក់ I, ខណ្ឌចំការមន, រាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា ។ ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះនេះ ក៏អាចផ្ញើតាមសំបុត្រមកកាន់អាសយដ្ឋាននេះបានដែរ ។ សម្រាប់ពត៌មានលំអិត ឬជំនួយក្នុងការបំពេញទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ សូមទាក់ទងមកកាន់អង្គភាពជនរងគ្រោះ តាមទូរស័ព្ទលេខ: 012 842861, 097 7424218 ឬ 023 214 291, ហ្វាក់លេខ: 023 214 295 ឬ ផ្ញើតាមអ៊ីម៉ែល: victimsunit@eccc.gov.kh ។


ECCC, National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia
Tel: +(855) 023 219 814 Fx: +(855) 023 219 841 Web: www.eccc.gov.kh